**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល
## ស្តីពី
## បច្ចុប្បន្នភាពជំងឺកូវីដ-១៩ នៅកម្ពុជា
## គិតត្រឹមម៉ោង ០៧:០០ ព្រឹក ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០ បង្ហាញថា មិនមានករណីព្យាបាលជាសះស្បើយ និងមិនមានករណីវិជ្ជមានកូវីដ-១៩ ថ្មី នោះទេ។ ដូច្នេះ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេសកម្ពុជា ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

– **អ្នកព្យាបាលជាសះស្បើយសរុបមានចំនួនកើនឡើងដល់ ១២០នាក់** (ស្មើនឹង ៩៨,៣៦% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់ នៅក្នុងចំនួននេះ មានស្រី ៣៧នាក់ និងបុរស ៨៣នាក់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្រ្តីជនជាតិចិន ០២នាក់ ស្រ្តីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអាមេរិកកាំង ០១នាក់ ស្រ្តីជនជាតិអាមេរិកកាំង ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១៩នាក់ (ក្នុងនេះ មានទារកអាយុ ០៤ខែ) ស្រ្តីជនជាតិបារាំង ២១នាក់ បុរសជនជាតិកាណាដា ០២នាក់ បុរសជនជាតិម៉ាឡេស៊ី ១៣នាក់ បុរសជនជាតិឥណ្ឌូនេស៊ី ០២នាក់ ស្រ្តីជនជាតិវៀតណាម ០៣នាក់ បុរសជនជាតិខ្មែរ ៤២នាក់ និងស្រ្តីជនជាតិខ្មែរ ០៧នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។

– **អ្នកដែលកំពុងសម្រាកព្យាបាលសរុបបានថយចុះមកនៅចំនួន ០២នាក់** (ស្រ្តី ០១នាក់ និងបុរស ០១នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ខេត្ត

– **អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន **១២២នាក់** (ស្រ្តី ៣៨នាក់ និងបុរស ៨៤នាក់)។

**២. មិនមានករណីជាសះស្បើយ និង មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ឡើយ** នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០។

**៣. ចំនួនសរុបវត្ថុសំណាកដែលបានធ្វើវិភាគ** ទាំងអស់មានចំនួន ១២,៣៧៨សំណាកសម្រាប់ទូទាំងប្រទេស (គិតចាប់តាំងពីខែមករា ឆ្នាំ២០២០ មកដល់ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០) ដែលក្នុងចំណោមប្រជាជនមួយលាននាក់ កម្ពុជាបានធ្វើតេស្តបានចំនួន ៧៦១សំណាក ហើយចំនួននេះ បានបង្ហាញថាកម្ពុជាបានអនុវត្តការធ្វើតេស្តរកវីរុសកូវីដ-១៩ បានច្រើនជាងបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ានយើងនេះ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: ([illegible]) [illegible] / ៨៨៤ ៩០៩

ធ្វើដំណើរមកពីបណ្តាប្រទេសផ្សេងៗដែលកំពុងមានការរាតត្បាតវីរុសកូវីដ-១៩ ត្រូវតែបន្តអនុវត្តឲ្យបានហ្មត់ចត់ដោយគ្រប់ផ្នែកពាក់ព័ន្ធ ពីព្រោះការនាំចូលវីរុសកូវីដ-១៩ មកក្នុងប្រទេសកម្ពុជា នៅតែជាកត្តាហានិភ័យសម្រាប់ព្រះរាជាណាចក្រកម្ពុជា ហើយក៏អាចជាហេតុផលនៃការកើតឡើងលើកទីពីរនៃការរាតត្បាតជំងឺកូវីដ-១៩ ប្រសិនបើយើងមានការធ្វេសប្រហែស ឬភ្លេចខ្លួនលើរាល់ចំណុចនៃកិច្ចការការពារដែលបានជម្រាបជូនខាងលើនេះ ហើយការដាក់នៅដាច់ដោយឡែក ការធ្វើតេស្ត ការព្យាបាល និងការតាមរកអ្នកដែលប៉ះពាល់ ដោយហ្មត់ចត់ជាទីបំផុត (Isolate – Test – Treat – Trace) ដែលជាការណែនាំរបស់អង្គការសុខភាពពិភពលោក នៅតែជាយុទ្ធសាស្ត្រនៃការឆ្លើយតបដ៏មានប្រសិទ្ធិភាព ដែលត្រូវប្រកាន់យកមកអនុវត្ត ជាពិសេសនៅក្នុងដំណាក់កាលរាតត្បាតនៃវីរុសកូវីដ-១៩។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញការកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។ ក្រសួងក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ** (TYDA) កាកបាទក្រហមកម្ពុជា សប្បុរសជននានា បណ្តាប្រទេសសហប្រតិបត្តិការអន្តរជាតិទ្វេភាគី និងពហុភាគី ព្រមទាំងដៃគូអង្គការជាតិនិងអន្តរជាតិទាំងអស់ ដែលបានចូលរួមចែករំលែកធនធាន ជាថវិកា សម្ភារៈ និងបរិក្ខារពេទ្យ សម្រាប់យុទ្ធនាការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

## ៤. ស្ថានភាពទូទៅនៃជំងឺកូវីដ-១៩ និង វិធានការដែលត្រូវប្រកាន់យកជាបន្ត ៖

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការកត់សម្គាល់ថា ស្ថានភាពជំងឺកូវីដ-១៩ នៅលើសកលលោក មិនទាន់មានភាពធូរស្រាលនៅឡើយទេ ដោយប្រទេសមួយចំនួននៅទ្វីបអាមេរិកក្តី ទ្វីបអឺរ៉ុបក្តី និងទ្វីបអាស៊ីយើងនេះក្តី មកទល់ពេលនេះ នៅតែនៅមានរកឃើញករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី បន្ថែមទៀត ដែលធ្វើឲ្យចំនួនអ្នកមានវីរុសកូវីដ-១៩ បានកើនឡើងរហូតទៅដល់ ៣,២៦៧,១៨៤នាក់ និងអ្នកស្លាប់មាន ២២៩,៩៧១នាក់ ហើយក្នុងរយៈពេល ២៤ម៉ោង មានអ្នកឆ្លងជំងឺនេះចំនួន ៩១,៩៧៧នាក់ និងអ្នកស្លាប់ចំនួន ៥,៧៩៩នាក់ នេះបើយោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោកចេញផ្សាយនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០ កន្លងទៅ។

រីឯស្ថានភាពនៅក្នុងប្រទេសកម្ពុជាវិញ ដូចបានជម្រាបជូននៅខាងលើនេះរួចហើយ ថ្វីត្បិតតែក្នុងរយៈពេល ០៣ សប្តាហ៍កន្លងមកនេះ មិនមានរកឃើញអ្នកឆ្លងវីរុសកូវីដ-១៩ អ្នកព្យាបាលជាសះស្បើយកើនដល់ ៩៨,៣៦% និងអ្នកជំងឺកំពុងព្យាបាលនៅសល់តែ ០២នាក់ (មិនមានស្លាប់) ក៏ពិតមែន ក៏ប៉ុន្តែ ស្ថានភាពជំងឺកូវីដ-១៩ គឺស្ថិតនៅក្នុងការប្រុងប្រយ័ត្នជាប់ជានិច្ចនៅឡើយទេ ហើយសូមបងប្អូនប្រជាពលរដ្ឋទាំងអស់ បង្កើន និងបន្តការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវ និង ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត ហើយត្រូវខិតខំអនុវត្តគ្រប់បែបយ៉ាងទាំងអស់ តាមបទបញ្ជារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងការណែនាំនានារបស់ក្រសួងសុខាភិបាល ដើម្បីកុំឱ្យមានការចម្លងរាតត្បាតចូលក្នុងសហគមន៍ ជាពិសេស ត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់នៅពេលធ្វើដំណើរ ចៀសវាងការរៀបចំពិធីដែលមានការជួបជុំគ្នាច្រើនកុះករ ដូចជាពិធីសាសនា ឬបុណ្យទាននានា ឬបើចាំបាច់ខានមិនបាននោះក៏ត្រូវកាត់បន្ថយឲ្យបានជាអតិបរិមានូវការធ្វើដំណើរចល័តរបស់បុគ្គលពីកន្លែងមួយទៅកន្លែងមួយ និងការជួបជុំគ្នាច្រើននេះផងដែរ។

ទន្ទឹមនឹងនោះ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវចេះផ្លាស់ប្តូរឥរិយាបថ និងទម្លាប់របស់ខ្លួន ដោយនៅចំពោះមុខការរាតត្បាតនេះ យើងត្រូវខិតខំប្រឹងប្រែងរៀបចំការរស់នៅតាមគន្លងថ្មីនៃជីវភាពធម្មតារបស់ខ្លួន ដើម្បីចៀសវាងការចម្លងរោគ ដូចជាការអនុវត្តន៍ឲ្យបានខ្ជាប់ខ្ជួននូវអនាម័យដៃស្អាត ដោយលាងសម្អាតជាមួយទឹកស្អាតនឹងសាប៊ូ ឬទឹកអាល់កុល ឬទឹកដែលលាងដៃ ឲ្យបានញឹកញាប់ ប្រើប្រាស់ម៉ាស់ (ក្នុងករណីចាំបាច់) ឬក្រម៉ា ឬកន្សែងដៃខ្ទប់មាត់ និង ច្រមុះ នៅពេលក្អកកណ្តាស់ រួចបោកគក់នឹងសាប៊ូ ហាលថ្ងៃសម្ងួតឲ្យបានល្អ ឬ បើប្រើក្រដាសជូតមាត់ ខ្ទប់មាត់ និង ច្រមុះ នៅពេលក្អកកណ្តាស់ រួចត្រូវបោះចោលក្នុងធុងសម្រាមឲ្យបានត្រឹមត្រូវ បរិភោគចំណីអាហារឆ្អិនល្អ ចៀសវាងនៅកន្លែងប្រមូលផ្តុំច្រើនគ្នា រក្សាគម្លាតសុវត្ថិភាពសង្គម និង គម្លាតសុវត្ថិភាពបុគ្គលឲ្យបានខ្ជាប់ខ្ជួន នៅតាមកន្លែងប្រមូលផ្តុំ និងនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ឬហាងនានា ហើយប្រសិនបើមានករណីសង្ស័យ ត្រូវរាយការណ៍តាមលេខ ១១៥ ជាបន្ទាន់។ បន្ថែមលើនេះ ការរឹតបន្តឹង និងការផ្អាកការធ្វើដំណើរមកពីប្រទេសចំនួន ០៦ប្រទេស មានប្រទេសអ៊ីតាលី អេស្ប៉ាញ អាល្លឺម៉ង់ អាមេរិក បារាំង និងអ៊ីរ៉ង់ ត្រូវបានពន្យាពេល និងបន្តធ្វើរហូតដល់ស្ថានភាពរាតត្បាតជំងឺកូវីដ-១៩មានការធូរស្រាល ក្រោយពីមានការវាយតម្លៃរួមគ្នារវាងក្រសួង សុខាភិបាល និងអង្គការសុខភាពពិភពលោក។

ដើម្បីបន្តទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា ការត្រួតពិនិត្យការធ្វើដំណើរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា នៅតាមច្រកចេញ-ចូលអន្តរជាតិទាំងអស់ និង វិធានការដែលបានដាក់ចេញសម្រាប់ការរឹតបន្តឹង និងផ្អាកការធ្វើដំណើរពីបណ្តាប្រទេសចំនួន ០៦ (ប្រទេសអ៊ីតាលី អេស្ប៉ាញ អាល្លឺម៉ង់ អាមេរិក បារាំង និងអ៊ីរ៉ង់) និងការ

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

## និន្នាការនៃចំនួនវិជ្ជមានកូវីដ-១៩ សរុបប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

### ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញ បែងចែកតាមសញ្ជាតិ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

## គិតដល់ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១២២ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ-១៩ នៅកម្ពុជា

**គិតដល់ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២០**

**ចំនួនករណីវិជ្ជមានកូវីដ-១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត**

**សរុប ១២២ ករណី**




ប្រភព៖ ក្រសួងសុខាភិបាល